# បច្ចេកទេសចិញ្ចឹមមាន់ស្រុកសម្រាប់ទីផ្សារ

## ការរៀបចំ និងសាងសង់ទ្រុងសម្រាប់មាន់

### តើយើងធ្វើទ្រុងថែរក្សាកូនមាន់យ៉ាងដូចម្តេច?






តួទ្រុងធ្វើពី ឈើ ឬ ឬស្សី

តួទ្រុងធ្វើពីឈើ និងសំណាញ់



### ការសាងសង់ទ្រុងមាន់ធំ (ពិន្ទុសកាត់មើលពីលើ)








សំយ៉ាបសម្រាប់រក្សាកូនមាន់ ប្រវែង ២,៥ម គុណ ៥ម



ធ្នើរសម្រាប់មាន់ដេក៖ កំពស់ពីដី ០,៧ម បន្ទា ០,៧ម និងចន្លោះបង្គងដេកនិមួយៗ ០,២៥ម





- ចំនួនសំបុកត្រូវសមស្របតាមចំនួនមេមាន់
- កុំឲ្យមានស្រមើរត្រូវដាក់បាតសំបុក៖ ថ្នាំជក់ ស្លឹកចេក ស្លឹកសាវម៉ាវព្រៃ ស្លឹកស្ពៅ ស្លឹកគ្រៃ ស្លឹកទាប ឬស្លឹកទន្ទ្រានខែត្រ

## ស្នូកចំណីមាន់







គុណសម្បត្តិស្នូកចំណីធ្វើពីធុងជ័រ៖

- មិនធ្វើឲ្យចំណីកំពប់ ខ្ជះខ្ជាយដោយការចឹកចំណីចោល និងមិនឲ្យកកាយ
- ចំណាយលុយតិចសម្រាប់ទិញ ឬធ្វើ
- អនាម័យល្អ

## ស្នូកទឹកមាន់



ស្នូកទឹកធ្វើពីកំប៉ុងជ័រ

ស្នូកទឹកធ្វើពីដើមឫស្សី



# គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD)

## ការជ្រើសរើសពូជមាន់ និងការគ្រប់គ្រងកូនមាន់

### តើត្រូវជ្រើសរើសមាន់សម្រាប់ចិញ្ចឹមរបៀបណា?



- កូនមាន់មានចលនាក្លៀវក្លា រហ័សរហួន
- មេបាសុខភាពល្អ និងមិនធ្លាប់កើតជម្ងឺធ្ងន់
- មិនត្រូវទិញកូនមាន់មានរោមស្អិត ពោះធ្លាក់ ឬរឹង និងមានពណ៌ខៀវ



- មានរាងល្អ ធំធាត់ រឹងមាំ មិនធ្លាប់កើតជម្ងឺធ្ងន់
- មានទម្ងន់ពី ២គ.ក្រ ឡើង
- រហ័សរហួន ពូកែជាន់មេ
- មានអាយុពី ៩ខែ ទៅ ៣ឆ្នាំ



- រូបរាងធំធាត់ រឹងមាំ និងមិនដែលកើតជម្ងឺធ្ងន់
- មានទម្ងន់ពី ១,២គ.ក្រ ឡើង
- អាយុពី ៧ខែ ទៅ ៣ឆ្នាំ

- មេផ្តល់ស៊ុត ១ឆ្នាំ បាន ៤ ទៅ ៥សារ
- ពង ១សារៗ មានស៊ុតពី ៨ ទៅ ១២គ្រាប់
- កូនញាស់យ៉ាងតិច ៨ក្បាល ក្នុង ១សំបុក

### វដ្តជីវិតមាន់



## តើយើងបំបែកកូនមាន់ពីមេនៅអាយុ ១០ថ្ងៃយ៉ាងដូចម្តេច?

ដាក់មេ និងកូនទើបញាស់ក្នុងទ្រុងកូនដែលមានក្រាលអង្កាម ឬកំទេចអាចម៌រណា



- យកមេចេញពេលកូនមាន់អាយុ១០ថ្ងៃ
- ត្រូវយកបាវ ឬក្រដាសបាំងជុំវិញទ្រុងកូនមាន់ដើម្បីរក្សាកំដៅកូនមាន់



បើត្រជាក់ខ្លាំង ឬពេលយប់ត្រូវបន្ថែមកំដៅដោយប្រើក្អមធ្យូងកំដៅ ឬអំពូលភ្លើង (មូល)



កូនមាន់អាយុបាន ១ខែ ព្រលែងឲ្យដើរស៊ីចំណីដោយសេរីនៅក្នុងទ្រុងបំប៉ន



## តើយើងអាចដឹងពីកំដៅក្នុងទ្រុងកូនមាន់យ៉ាងដូចម្តេច?

កូនមាន់ដើររកស៊ីធម្មតា

ប្រភពកំដៅ (អំពូល ឬក្អមធ្យូង)

កូនមាន់ផ្តុំ ឬដេកគរលើគ្នា



កំដៅល្មមគ្រប់គ្រាន់ | កំដៅខ្លាំងពេក (នៅឆ្ងាយពីប្រភពកំដៅ) | កំដៅត្រជាក់ខ្លាំង




កំដៅសម្រាប់មាន់ ៣៥-៣៧អង្សាសេ

# ចំណីអាហារសម្រាប់មាន់

## តើចំណីមាន់ផ្សំពីអ្វីខ្លះដើម្បីឲ្យមានគុណភាពល្អ និងមាន់លូតលាស់លឿន?



ចំណីមានគុណភាពល្អ ត្រូវមាន៖
ប្រូតេអ៊ីន ថាមពល វីតាមីន
និងសារជាតុរ៉ែ គ្រប់គ្រាន់

## តើសារធាតុចំណីទាំងនេះមានប្រភពមកពីណា ?

### ប្រូតេអ៊ីន




### ថាមពល




### វីតាមីន




### សារធាតុរ៉ែ

សំបកខ្យង ខ្ចៅ
លៀស គ្រំ...



# ការចិញ្ចឹមជន្លេនក្រហមសម្រាប់ជាចំណីបំប៉នបន្ថែម



### តើជន្លេនក្រហមមានសារៈប្រយោជន៍អ្វីខ្លះ?

- ជន្លេនជួយឲ្យមាន់ធំធាត់លឿន
- ជួយកាត់បន្ថយការចំណាយលើចំណីមាន់

### តើត្រូវចិញ្ចឹមជន្លេនយ៉ាងដូចម្តេចដើម្បីឱ្យលូតលាស់ល្អ?



1

- កន្លែងចិញ្ចឹមរាងចតុកោណកែង មានទទឹង ១,២ម បណ្តោយ ៣ម
- ជញ្ជាំងកំពស់ពីដី ៣តឹក
- ជញ្ជាំង និងបាតក្រាលដោយផ្ទាំងកៅស៊ូ និងចោះរន្ធនៅបាត

2



- ដាក់លាមកគោស្រស់កម្រាស់១តឹក
- ស្រោចទឹកលើលាមកគោឱ្យសើមល្មម

3



4



- ដាក់ពូជជន្លេនរាយលើលាមកគោ
- បន្ទាប់មកស្រោចទឹកពីលើបន្តិចទៀត
- ធ្វើដំបូលការពារកំដៅ និងភ្លៀងឱ្យបានជិតល្អ
- ធ្វើគម្របពីលើការពារការស៊ីបំផ្លាញពីសត្វផ្សេងៗ (សត្វគីង្គក់ ហឹង កង្កែប ថ្កែន...)
- បន្ថែម (ស្រោច) លាមកគោខាប់ (កូរលាយទឹក) ៣ ថ្ងៃ ម្តង

5

- ចិញ្ចឹមបាន ២ ខែអាចចូកជន្លេនឱ្យមាន់ស៊ីរាល់ថ្ងៃ
- មាន់១ក្បាលអាចស៊ី ២-៣ ជន្លេន ក្នុង១ថ្ងៃ
- ត្រូវចាក់លាមកគោបំពេញកន្លែងបានចូកជន្លេនឲ្យមាន់ស៊ី



6

# ការផ្ដល់ចំណីអាហារសម្រាប់មាន់

## តើត្រូវផ្ដល់ចំណីមាន់អាយុចាប់ពី១ខែឡើងយ៉ាងដូចម្ដេច?




៥០%




៥០%










ផ្ដល់បន្លែបន្ថែម សម្រាប់មាន់ ដោយព្យួរក្នុងទ្រុង

## ការផ្ដល់ចំណីកូនមាន់



- អាយុ ១ថ្ងៃ ទៅ ១៤ថ្ងៃ ផ្ដល់ចំណីផ្សំស្រេចសុទ្ធ (បារ៉ា)
- អាយុ ១៥ ទៅ ២១ថ្ងៃ ផ្ដល់ចំណីផ្សំស្រេច ដោយលាយចុងអង្ករ និងកន្ទក់ ២០%
- អាយុ ២២ ទៅ ៣០ថ្ងៃ ផ្ដល់ចំណីផ្សំស្រេច ដោយលាយចុងអង្ករ កន្ទក់ និងបន្លែ៣០%
- ផ្ដល់ទឹកឲ្យគ្រប់គ្រាន់ចាប់ពីញាស់

# គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD)

## ជីវៈសុវត្ថិភាព និងអនាម័យមាន់

បាចទឹកកំបោរសម្លាប់មេរោគ
ក្នុងទ្រុងបាន១អាទិត្យ
ទើបដាក់មាន់ចិញ្ចឹម



- ដាក់មាន់ជាក្រុមតាមអាយុ
- ផ្ទៃបាតទ្រុងស្ងួតជានិច្ច
- បាតទ្រុងត្រូវដាក់អង្កាម
- សំអាតលាមករៀងរាល់ថ្ងៃ
- សំអាតស្នូកចំណីរាល់ថ្ងៃ
- ផ្លាស់ប្តូរទឹកឲ្យបានញឹកញាប់



មាន់មកថ្មីត្រូវក្រុងទុក
២អាទិត្យ បើឃើញមាន
សុខភាពល្អទើបដាក់ចូល
គ្នា (ការពារឆ្លងជម្ងឺ)

មិនត្រូវឲ្យឈ្មួញទិញមាន់
និងអ្នកដទៃចូលក្នុងទ្រុង
មាន់ ឬក្នុងទីធ្លាចិញ្ចឹមមាន់









បើមាន់ងាប់ដោយជម្ងឺត្រូវ
យកទៅកប់ ឬដុតចោល



ដាក់ទឹកកំបោរនៅមាត់ទ្វារសម្រាប់
ជ្រលក់បាតជើងសម្លាប់មេរោគមុនចូល

# គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (TSTD)

## ការការពារជម្ងឺ និងទម្លាក់ព្រូនមាន់

### ជម្ងឺឆ្លងសំខាន់ៗបណ្ដាលឲ្យមាន់ឈឺ និងងាប់



ជម្ងឺញ៉ូវកាស ឬ ជង្កោកាច់



ជម្ងឺអុតមាន់
(ដុំពកលើក្បាល មុខ)



ជម្ងឺអាសន្នរោគ

### តើត្រូវការពារមាន់កុំឲ្យកើតជម្ងឺទាំងនេះយ៉ាងដូចម្ដេច?

- ចាក់វ៉ាក់សាំងការពារ មុនពេលសត្វឈឺ
- ចាក់វ៉ាក់សាំងការពារជម្ងឺមាន់ទាំងអស់ឲ្យបានយ៉ាងតិច៣មុខ ទៅតាមអាយុរបស់មាន់ (ជម្ងឺញ៉ូវកាស, អុត និងអាសន្នរោគ)
- ចាក់រំលឹកឡើងវិញឲ្យបានទៀងទាត់ ជាពិសេសមេបាពូជ
- វ៉ាក់សាំងដែលនៅសល់ពីការប្រើប្រាស់ត្រូវដុត ឬកប់ចោល

### កម្មវិធីចាក់វ៉ាក់សាំង និងទំលាក់ព្រូន

អាយុ ១ ទៅ ៣ ថ្ងៃ



បន្តក់វ៉ាក់សាំងញ៉ូវកាសនៅភ្នែក ប្រមុះ

អាយុ៧ ទៅ ១០ថ្ងៃ



ជួសស្លាបរងវ៉ាក់សាំងអុត



អាយុ២ខែ



ចាក់វ៉ាក់សាំងអាសន្នរោគនៅសាច់ដុំទ្រូង

អាយុ ២ខែកន្លះ



ទម្លាក់ព្រូន